**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីណែនាំ
# ស្តីពី
# វិធានការសុវត្ថិភាពនៅតាមរោងចក្រ សហគ្រាស ដែលអាចរងជំនន់ទឹកភ្លៀង

ដើម្បីបញ្ចៀសហានិភ័យការងារ និងបង្ការគ្រោះថ្នាក់ជាយថាហេតុណាមួយ ដែលបណ្តាលមកពីជំនន់ទឹកភ្លៀង ក្រសួងសូមណែនាំដល់ម្ចាស់និងនាយករោងចក្រ សហគ្រាស និងកម្មករនិយោជិត ដែលស្ថិតនៅតំបន់អាចរងនូវជំនន់ទឹកភ្លៀងដូចខាងក្រោម៖

## សម្រាប់ម្ចាស់ និងនាយករោងចក្រ សហគ្រាស

- ត្រូវតាមដានជាប្រចាំនូវការព្យាករណ៍ឧតុនិយម និងត្រៀមគោលការណែនាំអំពីសុវត្ថិភាព និងវិធីសាស្ត្រជម្លៀសខ្លួន នៅពេលមានទឹកលិច
- ត្រូវសហការ និងគោរពតាមការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ច និងត្រូវផ្អាកសង្វាក់ផលិតកម្មជាបណ្តោះអាសន្ន ក្នុងករណីមានទឹកជន់លិចខ្លាំងមិនអាចរក្សាសុវត្ថិភាពបាន
- ត្រូវពិនិត្យមើលប្រព័ន្ធអគ្គិសនី និងត្រូវបិទចរន្តអគ្គិសនីជាបណ្តោះអាសន្នភ្លាម ក្នុងករណីទឹកហូរចូលក្នុងអគារផលិតកម្ម និងបរិវេណរោងចក្រ សហគ្រាស
- ត្រូវយកចិត្តទុកដាក់ខ្ពស់ទីកន្លែង ដែលមានស្តុកទុកសារធាតុគីមី និងត្រូវបិទផុងរក្សាសារធាតុគីមីឱ្យបានជិតល្អ ដើម្បីចៀសវាងការលេចធ្លាយប៉ះពាល់ដល់សុខភាពរបស់កម្មករនិយោជិត និងប្រជាពលរដ្ឋ។

## សម្រាប់កម្មករនិយោជិត

- ត្រូវគោរពតាមការណែនាំ និងចាត់ចែងរបស់និយោជកពាក់ព័ន្ធនឹងវិធានការសុវត្ថិភាព
- ត្រូវចូលរួមសហការជាមួយនិយោជក ក្នុងការបង្ការទប់ស្កាត់ការហូរចូលនៃជំនន់ទឹកភ្លៀងទៅក្នុងអគារផលិតកម្ម និងបរិវេណរោងចក្រ សហគ្រាស
- ត្រូវនៅឱ្យឆ្ងាយពីប្រភព ឬខ្សែភ្លើងដែលចម្លងចរន្តអគ្គិសនី។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់និងនាយករោងចក្រ សហគ្រាស និងកម្មករនិយោជិត ដែលស្ថិតក្នុងតំបន់អាចរងជំនន់ទឹកភ្លៀងទទាំងអស់នឹងអនុវត្តតាមសេចក្តីណែនាំ។

*ថ្ងៃព្រហស្បតិ៍ ១៣ រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤*

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០*